ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
លេខ ..........១៨៤..........ក.ប/ប្រ.ក.ប.ស.ស

# ប្រកាស
# ស្តីពី
# ការកែសម្រួលប្រការ២ ប្រការ៤ ប្រការ៥ ប្រការ៦ ប្រការ៧ ប្រការ៨ និងប្រការ១០ នៃប្រកាសលេខ ១០៩ ក.ប/ប្រ.ក ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១៦ ស្តីពីតាងកាលិកថៃទាំសុខភាព

## រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៣ ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៣ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីវិសោធនកម្មមាត្រា ២៨ នៃច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៣៩៧/០១ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៩៧ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការងារ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៩០២/០១៨ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០២ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨១៥/៨៧២ ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១៥ ស្តីពីលក្ខន្តិកៈគតិយុត្តនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ ២៨៣ អនក្រ/បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ



អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣) ៨៨ ៤៣ ៧៥ និងទូរសារ :(០២៣)៨៨ ២៧ ៦៩

- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ/បក ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០០៧ ស្តីពីការបង្កើតបេឡាជាតិរបបសន្តិសុខសង្គម
- បានឃើញអនុក្រឹត្យលេខ០១ អនក្រ/បក ចុះថ្ងៃទី០៦ ខែមករា ឆ្នាំ២០១៦ ស្តីពីការបង្កើតរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាព សម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ
- បានឃើញប្រកាសលេខ ១០៩ ក.ប/ប្រក ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១៦ ស្តីពីតារកាលិកថែទាំសុខភាព
- យោងតាមសំណើរបស់ក្រុមប្រឹក្សាភិបាលនៃបេឡាជាតិរបបសន្តិសុខសង្គម

## សម្រេច

### ប្រការមួយ.-

ប្រការ២ ប្រការ៤ ប្រការ៥ ប្រការ៦ ប្រការ៧ ប្រការ៨ និងប្រការ១០ នៃប្រកាសលេខ ១០៩ ក.ប/ប្រ.ក ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១៦ ស្តីពីតារកាលិកថែទាំសុខភាព ត្រូវបានកែសម្រួលដូចតទៅ៖

### ប្រការ ២ថ្មី.-

វាក្យស័ព្ទសំខាន់ៗដែលប្រើនៅក្នុងប្រកាសនេះមានដូចតទៅ៖

- *តារកាលិកថែទាំសុខភាព* សំដៅដល់របបធានារ៉ាប់រង ដែលផ្តល់កញ្ចប់តារកាលិកសុខភាព និងសេវាបង្ការដែលបានកំណត់។
- *កញ្ចប់តារកាលិកសុខភាព* សំដៅដល់សេវាព្យាបាលថែទាំវេជ្ជសាស្ត្រ សេវាបញ្ជូនជនរងគ្រោះ សេវាបញ្ជូនសព និងប្រាក់បំណាច់ប្រចាំថ្ងៃ។
- *សេវាបង្ការសុខភាព* សំដៅដល់ការធ្វើរោគវិនិច្ឆ័យទាន់ពេលវេលា កំណត់អត្តសញ្ញាណអ្នកដែលមានហានិភ័យសុខភាព និងមានបញ្ហាសុខភាពជាក់លាក់ ការផ្តល់ប្រឹក្សា និងអន្តរាគមន៍ចាំបាច់ដទៃទៀត ដើម្បីការពារកុំឲ្យមានបញ្ហាសុខភាព មានជាអាទិ៍ ការស្រាវជ្រាវរកជំងឺ ការអប់រំសុខភាព និងកម្មវិធីចាក់ថ្នាំបង្ការ។
- *សេវាព្យាបាលនិងថែទាំវេជ្ជសាស្ត្រ* សំដៅដល់សេវាវេជ្ជសាស្ត្រ អមវេជ្ជសាស្ត្រ និងជំនួយវេជ្ជសាស្ត្រ។
- *សេវាវេជ្ជសាស្ត្រ* សំដៅដល់សេវាពិគ្រោះជំងឺក្រៅ និងសេវាសម្រាកពេទ្យ។
- *សេវាអមវេជ្ជសាស្ត្រ* សំដៅដល់សេវាមន្ទីរពិសោធន៍ និងរូបភាពវេជ្ជសាស្ត្រ។
- *សេវាជំនួយវេជ្ជសាស្ត្រ* សំដៅដល់ការព្យាបាលដោយស្ពំ និងដោយចលនា។
- *បច្ចេកទេសវិជ្ជាជីវៈវេជ្ជសាស្ត្រ* សំដៅដល់វិធីសាស្ត្រ នៃការធ្វើរោគវិនិច្ឆ័យ ការផ្តល់សេវាព្យាបាលថែទាំ ដែលផ្តល់ដោយអ្នកបញ្ចប់ការសិក្សាក្នុងវិស័យសុខាភិបាល ហើយត្រូវបានចុះបញ្ជិកាជាមួយគណៈវិជ្ជាជីវៈពេទ្យ និងត្រូវបានអនុញ្ញាតច្បាប់ឲ្យប្រកបមុខរបរតាមវិជ្ជាជីវៈ ដោយក្រសួងសុខាភិបាល។
- *សេវាស្តារនីតិសម្បទា* គឺជាសេវាព្យាបាលថែទាំវេជ្ជសាស្ត្រសម្រាប់របបថែទាំសុខភាព ក្នុងគោលបំណងជួយដល់ជនរងគ្រោះរក្សា ស្តារ ឬធ្វើឲ្យប្រសើរឡើងវិញ នូវសមត្ថ

ភាពជំនាញ និងមុខងារសម្រាប់ការរស់នៅប្រចាំថ្ងៃ និងជំនាញប្រាស្រ័យទាក់ទង ដែលបានបាត់បង់ ឬខូចខាតដោយសារជំងឺ ការរងរបួស ឬពិការភាព។

- *សល្យសាស្ត្រ* សំដៅដល់ការវះកាត់តាមរបៀបវិទ្យាសាស្ត្រក្នុងបំណងព្យាបាល។
- *មូលដ្ឋានសុខាភិបាល* សំដៅដល់អង្គភាពសុខាភិបាលសាធារណៈ ឬ ឯកជន ដែលទទួលស្គាល់ដោយក្រសួងសុខាភិបាល។
- *សម្រាកមាតុភាព* សំដៅដល់ការសម្រាកមុន និងក្រោយពេលសម្រាលកូន។
- *សេវាពិគ្រោះជំងឺក្រៅ* សំដៅដល់សេវាពិនិត្យ និងពិគ្រោះជំងឺក្រៅ ដោយមិនរាប់បញ្ចូលការសម្រាកព្យាបាលនៅក្នុងមន្ទីរពេទ្យ។
- ការសម្រាលកូន សំដៅដល់ ការឲ្យកំណើតទារកដែលមានអាយុចាប់ពី២៦ (ម្ភៃប្រាំមួយ)សប្តាហ៍ឡើងនៅក្នុងមូលដ្ឋានសុខាភិបាល។
- ប្រាក់បំណាច់ប្រចាំថ្ងៃ សំដៅដល់ ប្រាក់ដែលផ្តល់ជូនសម្រាប់រយៈពេលអាក់ខានការងារ ដោយសារការធ្លាក់ខ្លួនមានជម្ងឺ គ្រោះថ្នាក់ ឬលំហែមាតុភាព។
- ការព្យាបាលដោយខ្លួនឯង សំដៅដល់ ការព្យាបាលដោយគ្មានវេជ្ជបញ្ជាពីគ្រូពេទ្យដែលបានចុះកិច្ចព្រមព្រៀងជាមួយ ប.ស.ស លើកលែងតែករណីសង្គ្រោះបន្ទាន់។
- ឧបករណ៍ជំនួយភ្នែកសិប្បនិម្មិត សំដៅដល់ ឧបករណ៍វ៉ែនតា ឬ ឡង់ទីជំនួយភ្នែក (contact lens)។
- ឱសថសារវន្ត សំដៅដល់ មុខឱសថនៅក្នុងបញ្ជីឱសថសារវន្ត ដែលកំណត់ដោយក្រសួងសុខាភិបាលសម្រាប់មូលដ្ឋានសុខាភិបាលសាធារណៈ។
- អ្នកតំណាងជនរងគ្រោះ ឬអ្នកជម្ងឺ សំដៅដល់សាច់ញាតិឬសហព័ទ្ធរបស់សាមីខ្លួន។

**ប្រការ ៤ថ្មី..**

សេវាមិនរាប់បញ្ចូលក្នុងសេវាព្យាបាលវេជ្ជសាស្ត្រគឺៈ

១.ការព្យាបាលដោយមិនគិតថ្លៃ ដែលមានចែងក្នុងគោលនយោបាយសុខាភិបាលសាធារណៈ

២.ការថែទាំធ្មេញ (ការសំអាតធ្មេញ ការប៉ះធ្មេញ និងការដាក់ធ្មេញ)

៣.ការព្យាបាល និងការវះកាត់ប្តូរភេទ

៤.ការផ្សាំឬប្តូរសរីរាង្គផ្សេងៗ

៥.សេវាបង្កកំណើតដោយសិប្បនិម្មិត

៦.ការព្យាបាលដោយខ្លួនឯង

៧.ការព្យាបាលឬការវះកាត់ដើម្បីជាប្រយោជន៍នៃការកែលម្អផ្នែកណាមួយនៃរាងកាយ

៨.ឧបករណ៍ជំនួយភ្នែកសិប្បនិម្មិត និងការព្យាបាលដោយកាំរស្មីឡាស៊ែ

៩.ការព្យាបាលញៀនសុរា និងផ្តាច់គ្រឿងញៀន

១០.ការព្យាបាលអសមត្ថភាពផ្តល់កំណើត

១១.ការវះកាត់ដោយដាក់គ្រាប់ភ្នែកសិប្បនិម្មិត

១២.ការវះកាត់បេះដូង និងសសៃឈាមបេះដូង

១៣.ការលាងឈាម

១៤.ការពិនិត្យសុខភាពទូទៅ

ក្នុងករណីសង្គ្រោះបន្ទាន់សេវាដូចមានចែងខាងលើ ត្រូវបានផ្តល់ជូន។

**ប្រការ ៥ថ្មី..**

ការផ្តល់សេវាចំពោះជម្ងឺរ៉ាំរ៉ៃ ត្រូវធ្វើឡើងតែក្នុងមូលដ្ឋានសុខាភិបាលសាធារណៈ នឹងត្រូវប្រើប្រាស់ឱសថសារវន្តតែប៉ុណ្ណោះ។ ចំពោះឱសថព្យាបាលក្រៅពីបញ្ជីឱសថសារវន្ត ជាបន្ទុកចំណាយផ្ទាល់របស់អ្នកជម្ងឺ លើកលែងតែឱសថព្យាបាលជម្ងឺទឹកនោមផ្អែម និងជម្ងឺលើសសម្ពាធឈាម មិនមាននៅក្នុងបញ្ជីឱសថសារវន្ត និងការព្យាបាលជម្ងឺមហារីកដោយសារធាតុគីមី ត្រូវទូទាត់ថ្លៃតាមសេវាព្យាបាលនីមួយៗ។

**ប្រការ ៦ថ្មី..**

៦.១ ដើម្បីទទួលបានសេវាព្យាបាល និងថែទាំវេជ្ជសាស្ត្រ កម្មករនិយោជិតទាំងអស់ត្រូវបំពេញលក្ខខណ្ឌដូចតទៅ៖

ក.កំពុងបំពេញការងារក្នុងសហគ្រាស គ្រឹះស្ថាន ដែលបានចុះបញ្ជិកា ក្នុងបេឡាជាតិរបបសន្តិសុខសង្គមសម្រាប់របបសន្តិសុខសង្គមផ្នែកថែទាំសុខភាព និងមានប័ណ្ណសមាជិក ប.ស.ស ទោះបីជានិយោជកមិនទាន់បង់ភាគទានសម្រាប់ខែដំបូងក៏ដោយ។

ខ.បានបង់យ៉ាងតិច ០៦(ប្រាំមួយ)ខែ ក្នុងអំឡុងពេល១២(ដប់ពីរ)ខែចុងក្រោយគិតរហូតមកទល់ខែដែលមានបញ្ហាសុខភាពឬមាតុភាព។

ក្នុងករណីដែលសមាជិក ត្រូវបានបង់ភាគទាន០២(ពីរ)ខែជាប់គ្នាហើយ ប៉ុន្តែអស់កាតព្វកិច្ចបង់ភាគទាន សមាជិកមានសិទ្ធិទទួលសេវាព្យាបាល និងថែទាំវេជ្ជសាស្ត្ររយៈពេល ២(ពីរ)ខែ ថែមទៀត គិតពីកាលបរិច្ឆេទនៃការអស់កាតព្វកិច្ចបង់ភាគទាន។

៦.២ ដើម្បីទទួលបានប្រាក់បំណាច់ប្រចាំថ្ងៃ កម្មករនិយោជិតទាំងអស់ត្រូវបំពេញលក្ខខណ្ឌដូចតទៅ៖

- ត្រូវបានបង់ភាគទានផ្នែកថែទាំសុខភាពក្នុងរយៈពេល២(ពីរ)ខែជាប់គ្នា ឬ បានបង់យ៉ាងតិច០៦(ប្រាំមួយ)ខែ ក្នុងអំឡុងពេល១២(ដប់ពីរ)ខែចុងក្រោយគិតរហូតមកទល់ខែដែលមានបញ្ហាសុខភាព និងកំពុងបំពេញការងារ
- ត្រូវបានបង់ភាគទានបាន០៩ខែក្នុងអំឡុងពេល១២(ដប់ពីរ)ខែចុងក្រោយគិតរហូតមកទល់ខែដែលបានសម្រាលកូន។

**ប្រការ ៧ថ្មី..**

៧.១ កម្មករនិយោជិតដែលបានបំពេញលក្ខខណ្ឌដូចមានចែងក្នុងប្រការ៦ ចំណុច៦.២ មានសិទ្ធិទទួលបាន៖

- ការព្យាបាលដោយឥតគិតថ្លៃនៅមូលដ្ឋានសុខាភិបាលដែលបានចុះកិច្ចព្រមព្រៀងជាមួយបេឡាជាតិរបបសន្តិសុខសង្គម(ប.ស.ស) ត្រឹមរយៈពេល១៨០ថ្ងៃ (មួយ

រយប៉ែតសិប)ថ្ងៃ ក្នុងអំឡុងពេល១២(ដប់ពីរ)ខែដោយគិតតែរយៈពេលព្យាបាលដែលសម្រាកនៅក្នុងមន្ទីរពេទ្យ

- ប្រាក់បំណាច់ប្រចាំថ្ងៃ៧០%(ចិតសិបភាគរយ) នៃប្រាក់ឈ្នួលមធ្យមជាប់ភាគទានប្រចាំថ្ងៃរបស់សាមីជន សម្រាប់រយៈពេលអាក់ខានការងារដោយសារការសម្រាកព្យាបាលថែទាំជម្ងឺឬរបួស តាមវេជ្ជបញ្ជាមានរយៈពេលជាប់គ្នាលើសពី០៧(ប្រាំពីរ)ថ្ងៃ ដោយរាប់ចាប់ពីថ្ងៃទី១ ដែលកម្មករនិយោជិតបានចូលទៅមូលដ្ឋានសុខាភិបាល។ ការផ្តល់ប្រាក់បំណាច់នេះផ្តល់ជូនមិនលើស១៨០(មួយរយប៉ែតសិប)ថ្ងៃក្នុងរយៈពេល១២(ដប់ពីរ)ខែចុងក្រោយដោយមិនរាប់បញ្ចូលរយៈពេលសម្រាកមាតុភាព៩០(កៅសិប)ថ្ងៃ
- ប្រាក់បំណាច់ប្រចាំថ្ងៃ៧០%(ចិតសិបភាគរយ) នៃប្រាក់ឈ្នួលមធ្យមជាប់ភាគទានប្រចាំថ្ងៃរបស់សាមីជនសម្រាប់រយៈពេល៩០(កៅសិប)ថ្ងៃនៃការឈប់សម្រាកមុន និងក្រោយសម្រាលកូន។

៧.២ សេវាបញ្ជូនអ្នកជម្ងឺឬជនរងគ្រោះ និងបញ្ជូនសព

- សេវាបញ្ជូនអ្នកជម្ងឺ ឬជនរងគ្រោះ ត្រូវផ្តល់ជូនតែក្នុងករណីសង្គ្រោះបន្ទាន់ និងដោយរថយន្តគិលានសង្គ្រោះរបស់មូលដ្ឋានសុខាភិបាល ឬ តាមមធ្យោបាយផ្សេងទៀតដែលមានលិខិតបញ្ជាក់ច្បាស់លាស់
- សេវាបញ្ជូនសពឬបញ្ជូនអ្នកជម្ងឺធ្ងន់ធ្ងរព្យាបាលមិនជា អាចធ្វើតាមមធ្យោបាយបញ្ជូនរបស់មូលដ្ឋានសុខាភិបាល ឬប្រភេទមធ្យោបាយជាក់ស្តែងផ្សេងទៀត។

**ប្រការ ៨ថ្មី.-**

៨.១ ប្រាក់ឈ្នួលមធ្យម គឺជាផលចែកមធ្យមភាគនៃប្រាក់ឈ្នួលជាប់ភាគទាន ក្នុងរយៈពេលជាក់ស្តែងមិនលើស០៦(ប្រាំមួយ)ខែ មុនខែដែលមានបញ្ហាសុខភាពឬសម្រាលកូន។ ប្រាក់ឈ្នួលជាប់ភាគទានត្រូវបានកំណត់ក្នុងតារាងដូចមានចែងក្នុងឧបសម្ព័ន្ធ១នៃប្រកាសនេះ។

៨.២ ប្រាក់ឈ្នួលមធ្យមប្រចាំថ្ងៃ គឺជាផលចែកនៃប្រាក់ឈ្នួលមធ្យម ដូចមានចែងក្នុងចំណុច ៨.១ នឹង៣០(សាមសិប)ថ្ងៃ។

៨.៣ ការគណនាប្រាក់ឈ្នួលមធ្យម ដែលកំណត់នៅក្នុងប្រកាសនេះមានអានុភាពចំពោះតែការគណនាតាវកាលិកសន្តិសុខសង្គមប៉ុណ្ណោះ។

**ប្រការ ១០ថ្មី.-**

១០.១ សមាជិក ប.ស.ស ត្រូវទៅប្រើប្រាស់សេវាសុខាភិបាល នៅមូលដ្ឋានសុខាភិបាលដែលបានចុះកិច្ចព្រមព្រៀងជាមួយ ប.ស.ស។ ប.ស.ស នឹងទទួលខុសត្រូវទូទាត់ថ្លៃសេវាដូចមានកំណត់ក្នុងកញ្ចប់តាវកាលិកសុខភាព។ ប្រសិនបើ សមាជិក ប.ស.ស ទៅប្រើប្រាស់សេវាក្រៅពីមូលដ្ឋានសុខាភិបាលដែលបានចុះកិច្ចព្រមព្រៀងជាមួយ ប.ស.ស នោះ ប.ស.ស នឹងទូទាត់សងវិញតែក្នុងករណីសង្គ្រោះបន្ទាន់ប៉ុណ្ណោះ។ ការទាមទារតាវកាលិក ត្រូវធ្វើតាមទម្រង់ "**តាវកាលិកព្យាបាលនិងថែទាំវេជ្ជសាស្ត្រ**" ឬហៅថាទម្រង់ "៤.០២" ដូចមានចែងក្នុង

**ឧបសម្ព័ន្ធ២** នៃប្រកាសនេះ។ បែបបទនៃការទាមទារនេះត្រូវមានភ្ជាប់ជាមួយនូវឯកសារវេជ្ជសាស្ត្រ និង វិក្កយបត្រនានាព្រមទាំងឯកសារពាក់ព័ន្ធចាំបាច់ដទៃទៀត។

១០.២ ការទាមទារប្រាក់បំណាច់ប្រចាំថ្ងៃ ត្រូវធ្វើឡើងដោយអ្នកជម្ងឺ ឬជនរងគ្រោះ ឬ អ្នកតំណាងតាមទម្រង់"**ប្រាក់បំណាច់ប្រចាំថ្ងៃផ្នែកថែទាំសុខភាព**" ឬហៅថាទម្រង់ "៤.០៣" ដូចមានចែងក្នុងឧបសម្ព័ន្ធ៣នៃប្រកាសនេះ។ បែបបទនៃការទាមទារនេះត្រូវភ្ជាប់ជាមួយនូវលិខិតចេញបញ្ជាក់ដោយមូលដ្ឋានសុខាភិបាល ដែលបានចុះកិច្ចព្រមព្រៀងជាមួយ ប.ស.ស ដែលជនរងគ្រោះបានចូលទៅទទួលសេវាថែទាំព្យាបាល និង លិខិតសុំអនុញ្ញាតច្បាប់ចេញដោយគ្រូពេទ្យសហគ្រាស ដោយមានការយល់ព្រមពីនិយោជក ឬ អ្នកតំណាងសហគ្រាស គ្រឹះស្ថាននោះ។

១០.៣ សិទ្ធិនៃការទាមទារតាវកាលិកព្យាបាលនិងថែទាំវេជ្ជសាស្ត្រ និងប្រាក់បំណាច់ប្រចាំថ្ងៃមានអាជ្ញាយុកាលត្រឹមរយៈពេល ១២ (ដប់ពីរ)ខែ គិតចាប់ពីថ្ងៃមានបញ្ហាសុខភាពដំបូង។

**ប្រការពីរ.-**

ប្រកាសនេះមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ...........១១កើត...ខែ...ពិសាខ...ឆ្នាំច សំរឹទ្ធិស័ក ព.ស. ២៥៦១.
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី...២៦...ខែមេសា...ឆ្នាំ២០១៨

**រដ្ឋមន្ត្រី**

**អ៊ិត សំហេង**

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ សម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ
- ក្រុមប្រឹក្សាភិបាល នៃប.ស.ស
  "ដើម្បីជូនជ្រាប"
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

*ឧបសម្ព័ន្ធ៤ នៃប្រកាសលេខ...១៧៤ ក.ប/ប្រ.ក.ប.ស.ស...ចុះថ្ងៃទី...២៥...ខែ...កក្កដា...ឆ្នាំ២០១៨ ស្តីពីការកែសម្រួលប្រការ២ ប្រការ៤ ប្រការ៥ ប្រការ៦ ប្រការ៧ ប្រការ៨ និងប្រការ១០ នៃប្រកាសលេខ១០៩ ក.ប/ប្រ.ក ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១៦ ស្តីពីការលិកថែទាំសុខភាព*

# លិខិតសុំអនុញ្ញាតច្បាប់

ខ្ញុំបាទ/នាងខ្ញុំ ឈ្មោះ ............................................... អាយុ..........ឆ្នាំ មុខតំណែង ..............................

លេខអត្តសញ្ញាណកម្មករនិយោជិតៈ | | | | | | | | | | | | | | | |

បម្រើការងារ ផ្នែក .............................. ក្រុមទី............

## <u>សូមគោរពជូន</u>

**អគ្គនាយក នាយក ម្ចាស់ សហគ្រាស គ្រឹះស្ថាន** ......................................................................

**តាមរយៈ** ៖ .........................................................................................................................................

**កម្មវត្ថុ** ៖ .........................................................................................................................................

**មូលហេតុ** ៖ .........................................................................................................................................

**លិខិតភ្ជាប់** ៖ .........................................................................................................................................

សេចក្តីដូចបានជម្រាបជូនក្នុងកម្មវត្ថុ មូលហេតុ និងលិខិតភ្ជាប់ខាងលើសូម **លោក/លោកស្រី អគ្គនាយក នាយក ម្ចាស់ សហគ្រាស គ្រឹះស្ថាន** មេត្តាអនុញ្ញាតច្បាប់ឲ្យខ្ញុំបាទ/នាងខ្ញុំ បានឈប់សម្រាកចំនួន ............ថ្ងៃ គិតចាប់ពីថ្ងៃ.............. ទី.......... ខែ............ ឆ្នាំ........... រហូតដល់ថ្ងៃ............ ទី.......... ខែ................ ឆ្នាំ............... និងចូលធ្វើការវិញ នៅថ្ងៃ............ ទី......... ខែ................ ឆ្នាំ............... ។

អាស្រ័យដូចបានជម្រាបដូចខាងលើ សូម **លោក/លោកស្រី អគ្គនាយក នាយក ម្ចាស់ សហគ្រាស គ្រឹះស្ថាន** មេត្តាអនុញ្ញាតច្បាប់ឲ្យខ្ញុំបាទ/នាងខ្ញុំ ដោយអនុគ្រោះ ។

សូម **លោក/លោកស្រី អគ្គនាយក នាយក ម្ចាស់ សហគ្រាស គ្រឹះស្ថាន** មេត្តាទទួលនូវសេចក្តីគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ/នាងខ្ញុំ ។

............ថ្ងៃទី.........ខែ............ឆ្នាំ...........

បានឃើញ និងឯកភាព　　　　ស្នាមមេដៃនិងឈ្មោះសាមីខ្លួន

............ថ្ងៃទី........ ខែ........... ឆ្នាំ...........

**បានឃើញ និងឯកភាព**　　　　ហត្ថលេខានិងឈ្មោះគ្រូពេទ្យ

............ថ្ងៃទី........ ខែ.............ឆ្នាំ.............

**អគ្គនាយក នាយក ឬតំណាងសហគ្រាស**

**សម្រាប់មន្ត្រី ប.ស.ស**

លេខតាវកាលិក ..........................

ហត្ថលេខា ......../......../........

# ប្រាក់បំណាច់ប្រចាំថ្ងៃ
# ផ្នែកថែទាំសុខភាព

❶ នាមករណ៍សហគ្រាស៖..........................................................................................................

លេខអត្តសញ្ញាណសហគ្រាស៖

អាសយដ្ឋានផ្លូវលេខ.......... សង្កាត់(ឃុំ)..........................ខណ្ឌ(ស្រុក)......................... រាជធានី(ខេត្ត) ..........................

លេខទូរស័ព្ទ៖ អ៊ីម៉ែលE-Mail:........................................................................................

❷ គោត្តនាមនិងនាមកម្មករនិយោជិត៖........................................................................................

លេខអត្តសញ្ញាណកម្មករនិយោជិត៖

អាសយដ្ឋានផ្លូវលេខ.......... សង្កាត់(ឃុំ)..........................ខណ្ឌ(ស្រុក)......................... រាជធានី(ខេត្ត) ..........................

លេខទូរស័ព្ទ៖ អ៊ីម៉ែលE-Mail:........................................................................................

❸ ថ្ងៃខែឆ្នាំឈប់សម្រាកៈ ថ្ងៃទី.........ខែ..........ឆ្នាំ.......... ថ្ងៃខែឆ្នាំត្រឡប់ចូលបម្រើការងារៈ ថ្ងៃទី.........ខែ...........ឆ្នាំ..........

- ចំនួនថ្ងៃសម្រាកព្យាបាលក្នុងមន្ទីរពេទ្យ...........ថ្ងៃ -ចាប់ពីថ្ងៃខែឆ្នាំ ........../........../......... ដល់ ........../........../............
- ចំនួនថ្ងៃសម្រាកព្យាបាលនៅផ្ទះ.......................ថ្ងៃ -ចាប់ពីថ្ងៃខែឆ្នាំ ........../........../......... ដល់ ........../........../............

**✵ ព័ត៌មានលម្អិតសម្រាប់អ្នកតំណាងការទាមទារប្រាក់បំណាច់ប្រចាំថ្ងៃ ផ្នែកថែទាំសុខភាព**

❹ គោត្តនាមនិងនាមអ្នកតំណាង៖ ....................................................... ភេទ.......... ថ្ងៃខែឆ្នាំកំណើត........ /........./..........

អាសយដ្ឋានផ្លូវលេខ.......... សង្កាត់(ឃុំ)..........................ខណ្ឌ(ស្រុក)......................... រាជធានី(ខេត្ត) ..........................

លេខទូរស័ព្ទ៖

លេខអត្តសញ្ញាណប័ណ្ណ/លេខលិខិតឆ្លងដែន៖ ចុះថ្ងៃទី........ /........../.........

*ខ្ញុំសូមសន្យាថារាល់ព័ត៌មានដែលបានផ្តល់ជូនខាងលើពិតជាត្រឹមត្រូវប្រាកដមែន។*

ធ្វើនៅ.................... ថ្ងៃទី............ ខែ.............. ឆ្នាំ២០.........

**ស្នាមមេដៃអ្នកស្នើសុំ**

*** ឯកសារភ្ជាប់៖**

-អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ/លិខិតឆ្លងដែនជនរងគ្រោះនិងអ្នកស្នើសុំ
-វេជ្ជបញ្ជាសម្រាកព្យាបាល
-លិខិតសុំអនុញ្ញាតច្បាប់ ចេញដោយនិយោជក
-ឯកសារពាក់ព័ន្ធសមមូល

ឧបសម្ព័ន្ធ២ នៃប្រកាសលេខ១៥៤ ក.ប/ប្រ.ក.ប.ស.ស ចុះថ្ងៃទី២៩ ខែតុលា ឆ្នាំ២០១៨ ស្តីពីការកែសម្រួលប្រការ២ ប្រការ៤ ប្រការ៥ ប្រការ៦ ប្រការ៧ ប្រការ៨ និងប្រការ១០ នៃប្រកាសលេខ១០៩ ក.ប/ប្រ.ក ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១៦ ស្តីពីតាវកាលិកថែទាំសុខភាព

០៤.០២

**សម្រាប់មន្ត្រី ប.ស.ស**

លេខតាវកាលិក ☐☐☐☐☐/☐☐

ហត្ថលេខា ......./......./.......

# តាវកាលិកព្យាបាលនិងថែទាំវេជ្ជសាស្ត្រ
# ផ្នែកថែទាំសុខភាព

❶ នាមករណ៍សហគ្រាស៖ ..........................................................

លេខអត្តសញ្ញាណសហគ្រាស៖ ☐☐☐☐☐☐☐☐

អាសយដ្ឋានផ្លូវលេខ......... សង្កាត់(ឃុំ)......................... ខណ្ឌ(ស្រុក)......................... រាជធានី(ខេត្ត) .........................

លេខទូរស័ព្ទ៖ ☐☐☐☐☐☐☐☐☐☐ អ៊ីម៉ែលE-Mail:..........................................................

❷ គោត្តនាមនិងនាមកម្មករនិយោជិត៖ ..........................................................

លេខអត្តសញ្ញាណកម្មករនិយោជិត៖ ☐☐☐☐☐☐☐☐☐☐☐☐☐☐☐☐

អាសយដ្ឋានផ្លូវលេខ......... សង្កាត់(ឃុំ)......................... ខណ្ឌ(ស្រុក)......................... រាជធានី(ខេត្ត) .........................

លេខទូរស័ព្ទ៖ ☐☐☐☐☐☐☐☐☐☐ អ៊ីម៉ែលE-Mail:..........................................................

❸ ឈ្មោះមន្ទីរពេទ្យ/គ្លីនិកព្យាបាល៖ ..........................................................

អាសយដ្ឋានផ្លូវលេខ......... សង្កាត់(ឃុំ)......................... ខណ្ឌ(ស្រុក)......................... រាជធានី(ខេត្ត) .........................

ប្រភេទគ្រោះថ្នាក់ឬជម្ងឺ៖ ..........................................................

ចំនួនថ្ងៃសម្រាកព្យាបាល៖ ..............ថ្ងៃ ចាប់ពីថ្ងៃខែឆ្នាំ........ /........./.......... ដល់ថ្ងៃខែឆ្នាំ........ /........./..........

**✵ ព័ត៌មានលម្អិតសម្រាប់អ្នកតំណាងការទាមទារតាវកាលិកព្យាបាល និងថែទាំវេជ្ជសាស្ត្រ ផ្នែកថែទាំសុខភាព**

❹ គោត្តនាមនិងនាមអ្នកតំណាង៖ .......................................... ភេទ.......... ថ្ងៃខែឆ្នាំកំណើត........ /........./.........

អាសយដ្ឋានផ្លូវលេខ......... សង្កាត់(ឃុំ)......................... ខណ្ឌ(ស្រុក)......................... រាជធានី(ខេត្ត) .........................

លេខទូរស័ព្ទ៖ ☐☐☐☐☐☐☐☐☐☐

លេខអត្តសញ្ញាណប័ណ្ណ/លេខលិខិតឆ្លងដែន៖ ☐☐☐☐☐☐☐☐☐☐ ចុះថ្ងៃទី........ /........./.........

*ខ្ញុំសូមសន្យាថារាល់ព័ត៌មានដែលបានផ្តល់ជូនខាងលើពិតជាត្រឹមត្រូវប្រាកដមែន។*

ធ្វើនៅ.................. ថ្ងៃទី........... ខែ............. ឆ្នាំ២០.........

**ស្នាមមេដៃអ្នកស្នើសុំ**

*** ឯកសារភ្ជាប់៖**
-អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ/លិខិតឆ្លងដែនជនរងគ្រោះនិងអ្នកស្នើសុំ
-វេជ្ជបញ្ជាសម្រាកព្យាបាល
-វិក្កយបត្រចំណាយវេជ្ជសាស្ត្រ

ឧបសម្ព័ន្ធ១ នៃប្រកាសលេខ...១៨៤...ក.ប/ប្រ.ក.សស...ចុះថ្ងៃទី...២៥...ខែ...មេសា...ឆ្នាំ២០១៨ ស្តីពីការកែសម្រួលប្រការ២ ប្រការ៤ ប្រការ៥ ប្រការ៦ ប្រការ៧ ប្រការ៨ និងប្រការ១០ នៃប្រកាសលេខ១០៩ ក.ប/ប្រ.ក ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១៦ ស្តីពីការកាលិកថៃទាំសុខភាព

# តារាងប្រាក់ឈ្នួលជាប់ភាគទាន

| ថ្នាក់ | ចំនួនប្រាក់ឈ្នួលសរុប (រៀល) | ប្រាក់ឈ្នួលជាប់ភាគទាន (រៀល) |
|---|---|---|
| ១ | ២០០ ០០០ ចុះ | ២០០ ០០០ |
| ២ | ២០០ ០០១ - ២៥០ ០០០ | ២២៥ ០០០ |
| ៣ | ២៥០ ០០១ - ៣០០ ០០០ | ២៧៥ ០០០ |
| ៤ | ៣០០ ០០០១ - ៣៥០ ០០០ | ៣២៥ ០០០ |
| ៥ | ៣៥០ ០០១ - ៤០០ ០០០ | ៣៧៥ ០០០ |
| ៦ | ៤០០ ០០១ - ៤៥០ ០០០ | ៤២៥ ០០០ |
| ៧ | ៤៥០ ០០០១ - ៥០០ ០០០ | ៤៧៥ ០០០ |
| ៨ | ៥០០ ០០១ - ៥៥០ ០០០ | ៥២៥ ០០០ |
| ៩ | ៥៥០ ០០១ - ៦០០ ០០០ | ៥៧៥ ០០០ |
| ១០ | ៦០០ ០០០១ -៦៥០ ០០០ | ៦២៥ ០០០ |
| ១១ | ៦៥០ ០០១ - ៧០០ ០០០ | ៦៧៥ ០០០ |
| ១២ | ៧០០ ០០១ - ៧៥០ ០០០ | ៧២៥ ០០០ |
| ១៣ | ៧៥០ ០០១ - ៨០០ ០០០ | ៧៧៥ ០០០ |
| ១៤ | ៨០០ ០០១ - ៨៥០ ០០០ | ៨២៥ ០០០ |
| ១៥ | ៨៥០ ០០១ - ៩០០ ០០០ | ៨៧៥ ០០០ |
| ១៦ | ៩០០ ០០១ - ៩៥០ ០០០ | ៩២៥ ០០០ |
| ១៧ | ៩៥០ ០០១ - ១ ០០០ ០០០ | ៩៧៥ ០០០ |
| ១៨ | ១ ០០០ ០០០១ - ១ ០៥០ ០០០ | ១ ០២៥ ០០០ |
| ១៩ | ១ ០៥០ ០០១ - ១ ១០០ ០០០ | ១ ០៧៥ ០០០ |
| ២០ | ១ ១០០ ០០១ - ១ ១៥០ ០០០ | ១ ១២៥ ០០០ |
| ២១ | ១ ១៥០ ០០១ - ១ ២០០ ០០០ | ១ ១៧៥ ០០០ |
| ២២ | ១ ២០០ ០០១ ឡើង | ១ ២០០ ០០០ |